THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF STUDENT HEALTH**
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ះ

នៅពេលដែលយើងចូលមកកាន់ថ្នាក់រៀនតាមទម្លាប់វិញក្នុងឆ្នាំសិក្សាថ្មីនេះ សុខុមាលភាពរបស់សិស្ស និងបុគ្គលិកនៅតែជាកិច្ចសំខាន់បំផុតរបស់យើង។ លិខិតនេះផ្តល់ព័ត៌មានបន្ថែម និងព័ត៌មានថ្មីៗអំពីកិច្ចខិតខំជាបន្តរបស់យើង ដើម្បីរក្សាសិស្ស និងបុគ្គលិកឱ្យមានសុខភាពល្អ និងសុវត្ថិភាព។

ជាការដាស់តឿនទូទៅ សូមទុកក្មេងទាំងអស់ដែលមានរោគសញ្ញានៃជំងឺអ្វីមួយឱ្យនៅផ្ទះ។ លើសពីនេះទៀត ក្មេងដែលរង់ចាំលទ្ធផលតេស្តរកមេរោគ ខូវីដ-១៩ ត្រូវតែនៅផ្ទះរហូតដល់ពេលលទ្ធផលនៃការធ្វើតេស្តត្រូវបានបញ្ជាក់។

**<u>ធ្វើតេស្តដើម្បី លេង/សម្តែង</u>**

នៅដើមឆ្នាំសិក្សានេះ ក្រសួងអប់រំបានអនុវត្តកម្មវិធីធ្វើតេស្តរកមេរោគ ខូវីដ-១៩ ដែលតម្រូវឱ្យសិស្សវិទ្យាល័យដែលចូលរួមក្នុងកីឡា ឬសិល្បៈសម្តែងអ្វីមួយ ឱ្យធ្វើតេស្តពីរដងក្នុងមួយសប្តាហ៍។ ចាប់ផ្តើមនៅខែតុលា ពិធីការនេះនឹងពង្រីកថែមទៀតដើម្បីរួមបញ្ចូលសិស្សអនុវិទ្យាល័យ។ **ដូច្នេះ ចាប់ផ្តើមនៅខែតុលា សិស្សានុសិស្សដែលមិនបានចាក់ថ្នាំបង្ការរោគ ចាប់ពីថ្នាក់ទី៦ ដល់ ទី១២ ដែលចូលរួមក្នុងកីឡាដែលប៉ះគ្នាច្រើន ច្រៀងក្នុងក្រុមចម្រៀង ឬលេងជាក្រុមតន្ត្រីច្រើនជាង ៣ ថ្ងៃ ក្នុងមួយសប្តាហ៍ [ឧបករណ៍សម្រាប់ក្រុមតន្ត្រី ខ្លុយ ប៉ីត្រោក ប៉ី និងវង់ត្រែ (brass and woodwind instruments) តែប៉ុណ្ណោះ] នឹងត្រូវធ្វើតេស្តរកមេរោគ ខូវីដ-១៩ ពីរដង ក្នុងមួយសប្តាហ៍ នៅសាលារបស់ពួកគេ។**

**<u>ស្ថានភាពចាក់ថ្នាំបង្ការរោគរបស់សិស្ស</u>**

យើងខ្ញុំស្នើសុំមាតាបិតាដែលមានកូនអាយុ ១២ ឆ្នាំឡើងទៅ ដែលបានទទួលការចាក់ថ្នាំបង្ការរោគ ខូវីដ-១៩ រួចហើយ ឱ្យផ្ញើភស្តុតាងនៃការចាក់ថ្នាំបង្ការរោគ ប្រសិនបើលោកអ្នកមិនទាន់បានផ្ញើនៅឡើយ។ ដើម្បីបញ្ជូនភស្តុតាងនៃការចាក់ថ្នាំបង្ការរោគការពារជំងឺ ខូវីដ-១៩ គ្រាន់តែថតរូបកាតចាក់ថ្នាំបង្ការរោគរបស់សិស្ស ហើយផ្ញើតាមអ៊ីមែលមកការិយាល័យសេវាកម្មសុខភាពសិស្សរបស់យើង តាម

រយៈ 5vax@philasd.org។ **ការបញ្ជូនភស្តុតាងអំពីស្ថានភាពនៃការចាក់ថ្នាំបង្ការរោគមិនមែនជាតម្រូវការទេ ទោះយ៉ាងណាក៏ដោយ ការដឹងអំពីអត្រានៃការចាក់ថ្នាំបង្ការរោគនៅសាលារបស់យើងនឹងជួយក្នុងការកំណត់ថាតើសិស្សណាដែលត្រូវដាក់ឱ្យនៅដាច់ពីគេ និងប្រាប់ពីផែនការសុខភាព និងសុវត្ថិភាពនាពេលអនាគត។**

**<u>ព្រឹត្តិការណ៍នៃថ្នាំបង្ការរោគ</u>**
វិទ្យាសាស្ត្រច្បាស់ណាស់ ថ្នាំបង្ការរោគ ខូវីដ-១៩ គឺជាវិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីកាត់បន្ថយហានិភ័យនៃមេរោគ។ ខណៈពេលដែលយើងទទួលស្គាល់ថាការសម្រេចចិត្តដើម្បីចាក់ថ្នាំបង្ការរោគនៅតែជាជម្រើសដ៏ពិបាកសម្រាប់បុគ្គល និងក្រុមគ្រួសារមួយចំនួន យើងសង្ឃឹមថាលោកអ្នកនឹងពិចារណាទទួលការចាក់ថ្នាំបង្ការរោគសម្រាប់ខ្លួនលោកអ្នក និងអ្នកណាម្នាក់នៅក្នុងគ្រួសាររបស់លោកអ្នកដែលមានអាយុ ១២ ឆ្នាំឡើងទៅ។ ក្រសួងអប់រំ តាមការសហការជាមួយដៃគូរៀបចំផ្សេងៗ បន្តរៀបចំព្រឹត្តិការណ៍ចាក់ថ្នាំបង្ការរោគនៅសាលារបស់យើងទូទាំងទីក្រុង។ សូមមើល វិបសៃសម្រាប់ព័ត៌មានអំពីថ្នាំបង្ការរោគ ខូវីដ-១៩ (COVID-19 Vaccine information website) របស់យើង ដើម្បីស្វែងរក និងចុះឈ្មោះសម្រាប់ព្រឹត្តិការណ៍ដែលនៅជិតលោកអ្នក។

ក្រសួងអប់រំនឹងបន្តនូវការអនុវត្តតាម ពិធីការសុខភាព និងសុវត្ថិភាព ថ្មីៗ (updated health and safety protocols) របស់យើង ដែលរួមមាន សុវត្ថិភាពជាច្រើនស្រទាប់ -- អនាម័យដៃ ការពាក់ម៉ាស់ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការរោគ ការឃ្លាតឆ្ងាយពីគ្នា ការធ្វើតេស្តបុគ្គលិកទាំងអស់ប្រចាំសប្តាហ៍ ការធ្វើតេស្តសិស្សដែលមានរោគសញ្ញាដូចជា ខូវីដ និងអ្វីៗជាច្រើនទៀត។ សូមអរគុណចំពោះការចូលរួមចំណែករបស់លោកអ្នកដើម្បីឱ្យយើងទាំងអស់គ្នាមានសុខភាពល្អ និងសុវត្ថិភាព!

ដោយសេចក្តីស្មោះស្ម័គ្រ

Mercedes Gutierrez, MD, MPH
អ្នកគ្រប់គ្រងសេវាកម្មសុខភាពសិស្ស